# លំហូរជាមូលដ្ឋាននៃនីតិវិធីអនុវត្តហ៊ីប៉ូតែក

ថ្ងៃទី ២៦~២៧ ខែ ឧសភា ឆ្នាំ ២០១៦

SHIMANUKI Masao ជំនាញការ JICA

ដំណាក់កាល

ការរឹបអូស

១～៣



**ម្ចាស់បំណុលនៃការអនុវត្ត X ៖** លោកចៅក្រមនៃតុលាការអនុវត្តខ្ញុំដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែក ព្រោះ Y មិនបានសងប្រាក់មកឲ្យខ្ញុំទេ។

៤～៦



**ចៅក្រម ៖** OK! អញ្ចឹង ខ្ញុំនឹងចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ។ លោកស្រីក្រឡាបញ្ជី សូមធ្វើការផ្ទុកផ្ដាក់ចុះបញ្ជីអំពីការរឹបអូស។

៧



**ក្រឡាបញ្ជី ៖** OK! លោកមន្ត្រីចុះបញ្ជី សូមធ្វើការចុះបញ្ជីអំពីការរឹបអូស។

៨～៩



**មន្ត្រីចុះបញ្ជី៖** OK! ខ្ញុំនឹងធ្វើការចុះបញ្ជីអំពីការរឹបអូស។

១០



**ចៅក្រម ៖** OK! ដោយសារតែការចុះបញ្ជីអំពីការរឹបអូសត្រូវបានធ្វើរួចរាល់ហើយ ដូច្នេះ ខ្ញុំនឹងបញ្ជូនដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំទៅកូនបំណុលនៃការអនុវត្ត។



**កូនបំណុលនៃការអនុវត្ត Y ៖** ចប់ហើយ! ដីរបស់ខ្ញុំត្រូវបានគេរឹបអូសហើយ !

ការលក់

១១
～
១៨



**ចៅក្រម ៖** ម្ចាស់បំណុលដែលចង់ទទួលបានការបែកចំណែក សូមធ្វើការទាមទារការបែកចំណែក។ ម្យ៉ាងវិញទៀត អ្នកដែលមានចំណាប់អារម្មណ៍ចំពោះអចលនវត្ថុនេះ សូមមក ចូលរួមដេញថ្លៃទិញ។



**ពួកម្ចាស់បំណុល ៖** លោកចៅក្រមនៃតុលាការអនុវត្ត សូមធ្វើការបែកចំណែកមកឲ្យពួកយើងផង !



**ប្រជាជន ៖** អចលនវត្ថុនេះមើលទៅល្អដែរតើ តោះទៅចូលរួមការដេញថ្លៃទិញ !



**ចៅក្រម ៖** លោកអាជ្ញាសាលា សូមអនុវត្តការលក់។

១៩



**អាជ្ញាសាលា ៖** OK! អ្នកទាំងអស់គ្នា តើអ្នកទាំងអស់គ្នាហ៊ានដាក់តម្លៃប៉ុន្មានដែរ ដើម្បីទិញដីនេះ?.........អបអរសាទរ លោកស្រី Z លោកស្រីបានឲ្យតម្លៃដីនេះថ្លៃជាងគេ !

២០~២២



**ចៅក្រម ៖** OK! បើតាមការត្រួតពិនិត្យនីតិវិធីមកដល់ត្រឹមពេលនេះ ឃើញថាគ្មានបញ្ហាអ្វីនោះទេ ដូច្នេះ ខ្ញុំអនុញ្ញាត ធ្វើការលក់ដីនេះទៅឲ្យលោកស្រី Z ។
លោកស្រី Z សូមធ្វើការបង់ប្រាក់។

២៣



**អ្នកទិញ Z ៖** ចាស! ខ្ញុំទៅយកប្រាក់មក។

២៤



**ក្រឡាបញ្ជី ៖** លោកមន្ត្រីចុះបញ្ជី សូមធ្វើការចុះបញ្ជី ពីព្រោះប្រាក់ថ្លៃលក់ត្រូវបានបង់រួចរាល់ហើយ។

២៥



**មន្ត្រីចុះបញ្ជី ៖** OK! ខ្ញុំនឹងចុះបញ្ជី។

ការចែកចំណែក
២៦
～
២៩



**ចៅក្រម ៖** បាទ! អញ្ចឹង! ការអនុវត្តការចែកចំណែកនឹងចាប់ផ្ដើមក្នុងពេលខាងមុខនេះ។ ម្ចាស់បំណុលដែលអាចទទួលបានការចែកចំណែក និង កូនបំណុលនៃការអនុវត្តសូមមកចូលរួមនៅកាលបរិច្ឆេទនៃការចែកចំណែក។